អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# កីឡាមួយណា?

# Which Sport Is It?



Written by TukTuk

Illustrated by Hen Choven



« កាលពីយប់មិញ តើអ្នកបានមើលកីឡាស៊ីហ្គេមដែរឬទេ? » យ៉េកបានសួរទៅក្មេងៗ។



« ខ្ញុំបានឃើញគេលេងកីឡាមួយប្រភេទ ដែលខ្ញុំចូលចិត្ត។ ខ្ញុំដូចជាមិនចាំឈ្មោះវាជាភាសាខ្មែរទេ តែដឹងថា មានមនុស្សពីរនាក់វាយរបស់មួយទៅវិញទៅមក »។មករានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



ថាហើយ មករាក៏បានរត់ទៅយកគ្រាប់សីមួយមក។ ក្មេងៗក៏បាននាំគ្នាទាត់វាទៅឆ្ងាយ តាមដែលខ្លួនអាចធ្វើទៅបាន។

« មើលនែ៎! យើងអាចទាត់វាបានដល់ទៅ៣ម៉ែត្រឯណោះ! »



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើដៃ មិនមែនប្រើជើងនោះទេ »។
រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



ពួកគេត្រឡប់មកវិញជាមួយនឹងបាល់ទះមួយគ្រាប់ ហើយចាប់ផ្តើមដក់បាល់នោះជាមួយគ្នា។

« មើលនែ៎! យើងអាចដក់បាល់ទៅវិញទៅមកបានជាង១០ដងឯណោះ! »



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើរ៉ាកែត មិនមែនប្រើដៃនោះទេ »។

រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



នាងក៏រត់ទៅយករ៉ាកែតវាយសីម្តង។ ក្មេងៗក៏ប្រើរ៉ាកែតនោះវាយសីជាមួយគ្នា។

« មើលនែ៎! ពួកយើងអាចវាយវាទៅវិញទៅមកបានដល់ទៅ៥ដង ដោយមិនឱ្យគ្រាប់សីធ្លាក់ដល់ដីនោះទេ »។



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើគ្រាប់តូចមួយ មិនមែនគ្រាប់សីនោះទេ »។មករាក៏ឆ្លើយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



ក្មេងៗក៏បានទៅយករ៉ាកែតវាយប៉េងប៉ុងនិងគ្រាប់ពណ៌ទឹកក្រូចតូចមួយមក។
« តែយើងមិនមានតុឬសំណាញ់នោះទេ » រតនានិយាយដោយទឹកមុខក្រៀមក្រំ។






មករានិយាយ « តែយើងនៅតែលេងបានអីចឹង! » ហើយមករាក៏យករ៉ាកែតវាយប៉េងប៉ុងនោះឡើងលើ។
« មើលនែ៎! ខ្ញុំអាចត្រេះគ្រាប់ប៉េងប៉ុងបានដល់ទៅមួយនាទី ដោយមិនភ្លាត់ស្នៀតឡើយ! »





យ៉េកនិយាយ « ពិតជាល្អណាស់! តែនិយាយរួម កីឡាហ្នឹងគេលេងដោយប្រើដៃ មិនមែនប្រើជើង គេប្រើរ៉ាកែត ប្រើបាល់ មិនមែនប្រើគ្រាប់សី ហើយប្រើសំណាញ់ មិនមែនប្រើតុនោះទេ »។







រតនានិយាយ « អូ! ខ្ញុំមិនដែលឮពីកីឡាបែបនេះសោះ »។



យ៉េកនិយាយ « អូ! ខ្ញុំចាំបានហើយ! គេហៅថា កីឡាវាយកូនបាល់ »។

មករាសួរ « តើវាជាផ្នែកមួយនៃកីឡាស៊ីហ្គេមដែរឬទេ? »



« ត្រូវហើយ! វាដូចគ្នានឹងកីឡាវាយសីនិងវាយប៉េងប៉ុងអីចឹង។ ខ្ញុំស្គាល់ទីលានវាយកូនបាល់មួយកន្លែងហើយខ្ញុំក៏មានរ៉ាកែតនិងបាល់ផងដែរ តើអ្នកចង់លេងទេ? » ក្មេងទាំងពីរក៏ឆ្លើយ « ចង់លេង! ចង់លេង! »





ដូច្នេះ យ៉េកក៏បានបើកក៊ឺម៉កកង់បីដឹកពួកគេទៅទីលានវាយកូនបាល់។ មករានិយាយ « ខ្ញុំវាយបាល់មិនត្រូវសោះ! ពិតជាពិបាកណាស់ »។
« មិនអីទេ »។ យ៉េកក៏បន្ត « អ្នកអាចចាប់ផ្ដើមដោយបោះបាល់ឱ្យគ្នាទៅវិញទៅមក »។



ក្មេងទាំងពីរក៏បានធ្វើតាមពាក្យយ៉េកបានប្រាប់ ហើយក៏លេងបានល្អជាងមុន។

បន្តិចក្រោយមក ពួកគេអាចវាយបាល់ឆ្លងកាត់សំណាញ់ទៅវិញទៅមកបានយ៉ាងស្ទាត់ជំនាញ។



ក្រោយមក យ៉េកបានបើកទូរទស្សន៍មើលការប្រកួតកីឡាវាយកូនបាល់។ កីឡាករប្រទេសកម្ពុជាបានយកឈ្នះការប្រកួតនេះ ហើយពួកគេទាំងអស់គ្នាក៏បានស្រែកហូរ ជយោ...ជយោ...ជយោ...!





មករានិយាយ « ខ្ញុំចង់រៀនវាយកូនបាល់បន្តទៀត។
នៅពេលដែលខ្ញុំធំឡើង ខ្ញុំប្រហែលអាចចូលរួមប្រកួតនិងយកឈ្នះគេក្នុងកីឡាស៊ីហ្គេមដែរ! »៕

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប ទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉ន លោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្ហើន៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

ADV

មូលនិធិផ្តល់ដោយអង្គការTukTukសហគមន៍រ៉ូតារីក្លឹប និង ADV TENNIS។

សៀវភៅរឿងនេះគឺនិពន្ធដោយ Robert McCurdy និងRoberta Dahl ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង Sally Heinrich ដែលបានចូលរួមកែសម្រួល និងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្ហើន